**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខ** : ៣០ សសរ

**សេចក្តីសម្រេច**

**ស្តីពី**

**ការបង្កើតក្រុមការងារថ្នាក់ជាតិចុះមូលដ្ឋាន ដើម្បីត្រួតពិនិត្យ និងគាំទ្រ ការអនុវត្តកម្មវិធីនយោបាយ និងយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៤ របស់រាជរដ្ឋាភិបាលកម្ពុជា**

**រាជរដ្ឋាភិបាល**

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៧ ចុះថ្ងៃទី២៤ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៣០១/០៥ ចុះថ្ងៃទី១៩ ខែមីនា ឆ្នាំ២០០១ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់
- យោងកម្មវិធីនយោបាយ និងយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៤ របស់រាជរដ្ឋាភិបាល សម្រាប់នីតិកាលទី៦ នៃរដ្ឋសភា
- យោងតាមការចាំបាច់របស់រាជរដ្ឋាភិបាល

**សម្រេច**

**ប្រការ១ .-**

ត្រូវបានបង្កើតក្រុមការងារថ្នាក់ជាតិចុះមូលដ្ឋាន ដើម្បីត្រួតពិនិត្យ និងគាំទ្រការអនុវត្តកម្មវិធីនយោបាយ និងយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៤ របស់រាជរដ្ឋាភិបាលកម្ពុជា **នៅខេត្តក្រចេះ** ដែលមានសមាសភាពដូចខាងក្រោម៖

| | | |
|---|---|---|
| ១. ឯកឧត្តម កិត្តិបណ្ឌិត ពេជ្រ ប៊ុនធិន | រដ្ឋមន្ត្រី ក្រសួងមុខងារសាធារណៈ | ប្រធាន |
| ២. ឯកឧត្តម ជី ច័ន្ទ្រផល | រដ្ឋលេខាធិការ ក្រសួងមហាផ្ទៃ | អនុប្រធាន |
| ៣. ឯកឧត្តម ឆាន់ សាផាន | រដ្ឋលេខាធិការ ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ | សមាជិក |
| ៤. ឯកឧត្តម លី ផល្លា | រដ្ឋលេខាធិការ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ | សមាជិក |
| ៥. ឯកឧត្តម សាន់ សាប់អី | រដ្ឋលេខាធិការ ក្រសួងសុខាភិបាល | សមាជិក |
| ៦. ឯកឧត្តម ញាណ សារោ | រដ្ឋលេខាធិការ ក្រសួងធម្មការ និងសាសនា | សមាជិក |
| ៧. ឯកឧត្តម កែ គី | រដ្ឋលេខាធិការ ក្រសួងឧស្សាហកម្ម និងសិប្បកម្ម | សមាជិក |
| ៨. ឯកឧត្តម ឈឹម សៅគី | រដ្ឋលេខាធិការ ក្រសួងអភិវឌ្ឍន៍ជនបទ | សមាជិក |
| ៩. ឯកឧត្តម ខៀវ ច័ន្ទប៊ុនធឿន | រដ្ឋលេខាធិការ ក្រសួងមុខងារសាធារណៈ | សមាជិក |
| ១០. ឯកឧត្តម ថៅ ផល្លី | អនុរដ្ឋលេខាធិការ ក្រសួងការពារជាតិ | សមាជិក |
| ១១. ឯកឧត្តម កាទើ មហាំម៉ាត់ណោសស្រី | អនុរដ្ឋលេខាធិការ ក្រសួងទេសចរណ៍ | សមាជិក |
| ១២. លោកជំទាវ ពេជ ពិទូរ្យរដ្ឋា | អនុរដ្ឋលេខាធិការ ក្រសួងកិច្ចការនារី | សមាជិក |
| ១៣. ឯកឧត្តម ប៉ែន សុវិជាតិ | អនុរដ្ឋលេខាធិការ ក្រសួងពាណិជ្ជកម្ម | សមាជិក |
| ១៤. ឯកឧត្តម ព្រុំ ច័ន្ទសុវណ្ណារី | អនុរដ្ឋលេខាធិការ ក្រសួងសាធារណការ និងដឹកជញ្ជូន | សមាជិក |
| ១៥. ឯកឧត្តម អ៊ឹម ស៊ីថុល | អនុរដ្ឋលេខាធិការ ទីស្តីការគណៈរដ្ឋមន្ត្រី | សមាជិក |
| ១៦. ឯកឧត្តម ម៉ែន សាម៉ន | អនុរដ្ឋលេខាធិការ ក្រសួងព័ត៌មាន | សមាជិក |
| ១៧. ឯកឧត្តម លាង ប៊ុនរិទ្ធ | អនុរដ្ឋលេខាធិការ ក្រសួងព័ត៌មាន | សមាជិក |
| ១៨. ឯកឧត្តម យន់ ខៀន | អនុរដ្ឋលេខាធិការ ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ | សមាជិក |
| ១៩. ឯកឧត្តម ម៉ី លីហួត | អនុរដ្ឋលេខាធិការ ក្រសួងធនធានទឹក និងឧតុនិយម | សមាជិក |
| ២០. ឯកឧត្តម សុខ សុយ៉ុន | អនុរដ្ឋលេខាធិការ ក្រសួងផែនការ | សមាជិក |
| ២១. ឯកឧត្តម គង់ ចាន់ | អនុរដ្ឋលេខាធិការ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ | សមាជិក |
| ២២. ឯកឧត្តម ឧត្តមសេនីយ៍ឯក មែ ស៊ីខេងវ៉ាន់ឌី | អគ្គនាយករង នៃក្រសួងមហាផ្ទៃ | សមាជិក |
| ២៣. ឯកឧត្តម ឧត្តមសេនីយ៍ឯក ឈូន ថាវរិទ្ធ | មេបញ្ជាការរង នៃក្រសួងការពារជាតិ | សមាជិក |
| ២៤. ឯកឧត្តម ឧត្តមសេនីយ៍ឯក ឌី ផេន | មេបញ្ជាការរង នៃក្រសួងការពារជាតិ | សមាជិក |
| ២៥. ឯកឧត្តម វង្ស ប៊ុនឥន្ទ្រាវុធ | ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជាអគ្គនាយក នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | សមាជិក |
| ២៦. ឯកឧត្តម សៅ ឡែន | អគ្គនាយក នៃក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា | សមាជិក |
| ២៧. ឯកឧត្តម បណ្ឌិត ជី ឡាយមិថុនា | សាកលវិទ្យាធិការ នៃសាកលវិទ្យាល័យក្រចេះ ក្រសួងអប់រំ យុវជន និងកីឡា | សមាជិក |
| ២៨. ឯកឧត្តម ឈាវ ណាក់ | ទីប្រឹក្សា ក្រសួងមហាផ្ទៃ | សមាជិក |
| ២៩. ឯកឧត្តម ចាន់ រស្មី | អគ្គនាយករង នៃក្រសួងទំនាក់ទំនងជាមួយ រដ្ឋសភា-ព្រឹទ្ធសភា និងអធិការកិច្ច | សមាជិក |

| | | |
|---|---|---|
| ៣០. **លោកបណ្ឌិត ឌី សមស៊ីដេត** | អគ្គនាយករង នៃក្រសួងអប់រំ យុវជន និងកីឡា | សមាជិក |
| ៣១. **លោក សុខ សុហោមា** | អគ្គនាយករង នៃក្រសួងអប់រំ យុវជន និងកីឡា | សមាជិក |
| ៣២. **លោក នង សារ៉េត** | អគ្គនាយករង នៃក្រសួងរ៉ែ និងថាមពល | សមាជិក |
| ៣៣. **លោក ហ៊ីង លីហៃ** | អគ្គនាយករង នៃក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ | សមាជិក |
| ៣៤. **លោក ជូរ ជេតទីវន្ត** | អគ្គនាយករង នៃក្រសួងឧស្សាហកម្ម និងសិប្បកម្ម | សមាជិក |
| ៣៥. **លោក ចាតស្វ សុភ័ក្រ** | អគ្គនាយករង នៃក្រសួងឧស្សាហកម្ម និងសិប្បកម្ម | សមាជិក |
| ៣៦. **លោក ហុង បញ្ញារិទ្ធ** | អគ្គាធិការរង នៃក្រសួងពាណិជ្ជកម្ម | សមាជិក |
| ៣៧. **លោក ហេង សុផាត** | ប្រធាននាយកដ្ឋាន នៃក្រសួងមហាផ្ទៃ | សមាជិក |
| ៣៨. តំណាងក្រសួងយុត្តិធម៌ | | សមាជិក |
| ៣៩. តំណាងក្រសួងបរិស្ថាន | | សមាជិក |
| ៤០. តំណាងក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ | | សមាជិក |
| ៤១. តំណាងក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ | | សមាជិក |
| ៤២. តំណាងរដ្ឋលេខាធិការដ្ឋានអាកាសចរណ៍ស៊ីវិល | | សមាជិក |

**ប្រការ២.**_

អភិបាលនៃគណៈអភិបាលខេត្តត្រូវបានប្រគល់ភារកិច្ចជាអនុប្រធានអចិន្ត្រៃយ៍ក្រុមការងារថ្នាក់ជាតិប្រចាំខេត្តរបស់ខ្លួន។

តួនាទី ភារកិច្ច របៀបរបបការងាររបស់ក្រុមការងារត្រូវកំណត់ដោយសេចក្តីណែនាំរបស់រាជរដ្ឋាភិបាលកម្ពុជា។

ប្រធានក្រុមការងារមានសិទ្ធិសម្របសម្រួលជាមួយក្រសួង ស្ថាប័ននានា ដើម្បីចាត់មន្ត្រី ឲ្យចូលរួមក្នុងក្រុមការងារ។

**ប្រការ៣.**_

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីគ្រប់ក្រសួង ប្រធានគ្រប់ស្ថាប័ន រដ្ឋបាលខេត្តក្រចេះ និងសាមីខ្លួន ដូចមានចែងក្នុងប្រការ១ ត្រូវទទួលបន្ទុកអនុវត្តសេចក្តីសម្រេចនេះ ឲ្យមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃ ពុធ ១ កើត ខែ ផល្គុន ឆ្នាំច សំរឹទ្ធិស័ក ព.ស ២៥៦២

រាជធានីភ្នំពេញ ថ្ងៃទី ៦ ខែ មីនា ឆ្នាំ២០១៩

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

កន្លែងទទួលៈ

- *ក្រសួងព្រះបរមរាជវាំង*
- *អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ*
- *អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*
- *អគ្គលេខាធិការដ្ឋានរដ្ឋសភា*
- *ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី*
- *ខុទ្ទកាល័យសម្តេច ឯកឧត្តម លោកជំទាវ ឧបនាយករដ្ឋមន្ត្រី*
- *រាជកិច្ច*
- *ឯកសារ-កាលប្បវត្តិ*